


ចែកជូនដោយឥតគិតថ្លៃ

# ធម្មជាតិ និង ជីវិត

# NATURE AND LIFE

ព្រឹត្តិបត្រប្រចាំពីរខែ Bi-monthly Newsletter

ឆ្នាំទី១២_លេខ៨៥ ខែមករា_កុម្ភៈ ២០០៨



ការដ្ឋានស្តុកឈើរបស់ក្រុមហ៊ុន ជីជីវើល
GG World Group



ដើមជ័រទ្បោះរបស់អ្នកភូមិកងណាកដែលអាចនឹងបាត់បង់



ដំណើរកំសាន្តរបស់ភ្ញៀវជាតិ-អន្តរជាតិនៅ
សហគមន៍ទេសចរណ៍ធម្មជាតិ បូរីអូរស្វាយ

## អត្ថបទខាងក្នុង ទំព័រ

១- ការអនុវត្តច្បាប់ធូររលុងប៉ះពាល់ដល់ស្មារតីអភិរក្ស របស់សហគមន៍ ០៣
២- ក្រុមហ៊ុនដីសម្បទានពីរកំពុងយាយីការរស់នៅរបស់ ប្រជាជនឃុំអូរស្វាយ និងកោះស្នែង ០៦
៣- អ្នកភូមិកងណាកប្រឈមមុខនឹងការបាត់បង់វប្បធម៌ នៃការចិញ្ចឹមជីវិត ១២
៤- អ្វីខ្លះដែលបណ្តាលចិត្តអ្នកឱ្យមកកំសាន្តនៅ សហគមន៍ទេសចរណ៍ធម្មជាតិ បូរីអូរស្វាយ ១៧
៥- អត្ថបទស្រាវជ្រាវ ២៤
៦- ចំណេះដឹងទូទៅ: សំណួរ-ចម្លើយ ២៧
៧- សង្ខេបព័ត៌មាន ៣១
៨- កំណាព្យ: ទំនួញព្រៃឈើ ៣៤

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ មានគោលដៅ ធានាអោយបាននូវការថែទាំ និងការពារបរិស្ថាន និងធនធានធម្មជាតិ ប្រកបដោយសមធម៌ក្នុង ព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅរកនិរន្តរភាពនៃ ការប្រើប្រាស់ និងការចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋ និងកូនខ្មែរជំនាន់ក្រោយ ។

**សមាគមថែរក្សាបរិស្ថាន និង វប្បធម៌ (សេប៉ា_CEPA)** បានបង្កើតឡើងនៅឆ្នាំ ១៩៩៥ ដោយនិស្សិតមួយក្រុម ជាអង្គការមិនមែនរដ្ឋាភិបាល មិនរកកំរៃ មិនពាក់ព័ន្ធនឹងគណបក្សនយោបាយ ឬក្រុមនយោបាយណាមួយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងត្រូវបានទទួលស្គាល់ដោយក្រសួងមហាផ្ទៃនៅឆ្នាំ១៩៩៦ ។

**ទស្សនៈវិស័យ**

សេប៉ាប្រាថ្នាចង់បាននូវ : សង្គមឯករាជ្យមួយដែលថែរក្សាបាននូវវប្បធម៌ និងបរិស្ថានដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយនិរន្តរភាព ស្ថិរភាព និងសុវត្ថិភាពសំរាប់កូនខ្មែរជំនាន់ក្រោយ។

**គោលដៅ**

ធានាអោយបាននូវការថែទាំ និងការពារបរិស្ថាន និងការប្រើប្រាស់ប្រកបដោយសមភាព និងសមធម៌នៃធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍដែលមានតុល្យភាពរវាងបរិស្ថាន សង្គម និងសេដ្ឋកិច្ច។

**បេសកកម្មរបស់សេប៉ា**

- ធ្វើកិច្ចសហប្រតិបត្តិការជាមួយថ្នាក់មូលដ្ឋាន និងរាជរដ្ឋាភិបាលដើម្បីលើកកម្ពស់សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រជាពលរដ្ឋ និងជំរុញអោយមានការការពារបរិស្ថាន និងវប្បធម៌របស់ខ្លួនតាមរយៈការស្រាវជ្រាវ ការអប់រំ ការផ្លាស់ប្តូរព័ត៌មាន-បទពិសោធន៍ និងការបណ្តុះបណ្តាលសកម្មជន។
- បង្កើននូវឱកាសសំរាប់សហគមន៍ក្នុងការលើកស្ទួយជីវភាពរបស់ពួកគាត់ និងអនុវត្តនូវគោលការណ៍សមភាព និងសមធម៌រវាងបុរស និងនារីដើម្បីធានាបាននូវការថែរក្សាប្រពៃណី វប្បធម៌ និងការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព។
- ពង្រឹងនូវសិទ្ធិរបស់ប្រជាជនមូលដ្ឋានក្នុងការប្រើប្រាស់ និងគ្រប់គ្រងធនធានធម្មជាតិប្រកបដោយសមភាព និងសមធម៌។
- ជំរុញការងារបណ្តាញក្នុងការទំនាក់ទំនងជាមួយនឹងអ្នកពាក់ព័ន្ធដើម្បីធានាបាននូវសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងថែរក្សានូវវប្បធម៌អន្តោគ្រាម ។

**សកម្មភាព និងយុទ្ធសាស្ត្រ**

- ▪កម្មវិធីការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព (គម្រោងសហគមន៍ព្រៃឈើ គម្រោងសហគមន៍នេសាទ គម្រោងសហគមន៍ទេសចរណ៍ធម្មជាតិ)
- ▪កម្មវិធីតស៊ូមតិដើម្បីការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព (គម្រោងគ្រប់គ្រងធនធានទឹកដោយនិរន្តរភាព គម្រោងតស៊ូមតិ និងបណ្តាញ និងគម្រោងព័ត៌មាន និងទំនាក់ទំនង)
- ▪កម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស (គម្រោងបណ្តុះបណ្តាលសកម្មជនបរិស្ថាន និងសហគមន៍ គម្រោងស្រាវជ្រាវសាលាភូមិ)








# ការអនុវត្តច្បាប់ធូររលុងប៉ះពាល់ដល់ស្មារតីអភិរក្សរបស់សហគមន៍

ធនធានធម្មជាតិនៅក្នុងប្រទេសកម្ពុជាមានច្រើនរាប់មិនអស់ លើដី ក្នុងដី ក្នុងទឹក ព្រៃឈើ រ៉ែ មច្ឆជាតិ ។ល។ នាសតវត្សចុងក្រោយនេះ ធនធានធម្មជាតិទាំងនោះត្រូវបានប្រើប្រាស់យ៉ាងច្រើន ក្នុងនោះមានធនធានជាច្រើនត្រូវបានដកហូតស្ទើរតែបាត់បង់ទាំងស្រុងក្នុងអំឡុង២ទសវត្សចុងក្រោយនេះ ។

ការដកហូត ឬប្រើប្រាស់ធនធានធម្មជាតិទាំងនោះបានធ្វើឡើងក្នុងគោលបំណងដែលមានកំរិតផ្សេងៗគ្នាដូចជា ដើម្បីបំរើផលប្រយោជន៍ផ្ទាល់ខ្លួន គ្រួសារ ឬប្រទេសជាតិ ។ ទង្វើទាំងនេះបានធ្វើឡើងពេលខ្លះប្រកបដោយវិចារណញ្ញាណ និងពេលខ្លះដោយភាពអន្តរាយ ។ ការដកហូត ឬការប្រើប្រាស់នូវធនធានមួយអាចធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិផ្សេងមួយទៀតទាំងដោយផ្ទាល់ និងប្រយោល ឧទាហរណ៏ការបាត់បង់ព្រៃឈើប៉ះពាល់ដល់ការរស់នៅ និងការចិញ្ចឹមជីវិតរបស់សត្វព្រៃ ការសាងសង់ទំនប់វារីអគ្គិសនីប៉ះពាល់ដល់ធនធានមច្ឆជាតិដែលឈានទៅប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់ប្រជាជន ។ល ។

ដោយយល់ឃើញពីភាពអន្តរាយទាំងនេះហើយទើបរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឱ្យមាននូវច្បាប់ អនុក្រឹត្យ និងបទដ្ឋានច្បាប់ជាច្រើនទៀតដើម្បីធានាឱ្យមានការដកហូត និងប្រើប្រាស់ធនធានធម្មជាតិទាំងឡាយប្រកបដោយគតិបណ្ឌិត គឺធានាឱ្យមាននិរន្តរភាពក្នុងការប្រើប្រាស់រួមបញ្ចូលទាំងការអភិរក្ស និងការស្តារឡើងវិញនូវការបាត់បង់ ។ ដោយសារវិសាល-ភាពនៃធនធានធម្មជាតិ និងដើម្បីធានាឱ្យបាននូវប្រសិទ្ធិភាពក្នុងការអភិរក្ស និងការប្រើប្រាស់

ប្រកបដោយនិរន្តរភាព វិមជ្ឈការនៃការគ្រប់គ្រងធនធានធម្មជាតិបានថែងឡើងដោយរាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យប្រជាជនមូលដ្ឋានគ្រប់គ្រងធនធានធម្មជាតិដោយផ្ទាល់តាមរយៈការចងក្រងជាសហគមន៍ដូចដែលយើងឃើញជាឧទាហរណ៍ស្រាប់មាន សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ។

រហូតមកដល់ពេលនេះ សហគមន៍ច្រើនរាប់រយបានបង្កើតឡើងដោយមានការជួយជ្រោមជ្រែងពីសំណាក់អង្គការជាតិ និងអន្តរជាតិផ្សេងនានា។ សហគមន៍បានបំពេញភារកិច្ចរបស់ខ្លួនជាជំហាន១ និងធ្វើការផ្លាស់ប្តូរនូវទំលាប់ពីការដកហូត និងប្រើប្រាស់ធនធានធម្មជាតិដោយអនាធិបតេយ្យ មករកការប្រើប្រាស់ដោយមានផែនការ និងវិធីសាស្ត្រច្បាស់លាស់ដើម្បីធានាឱ្យបាននូវនិរន្តរភាព។ ក្នុងចំណោមកិច្ចប្រឹងប្រែងទាំងនោះ ការអភិរក្សដើរតួនាទីដ៏សំខាន់មួយដែលធានាឱ្យមានតុល្យភាពរវាងការប្រើប្រាស់ ការថែទាំ និងការស្តារឡើងវិញ។ ការបណ្តុះបណ្តាលស្មារតីអភិរក្សដល់សហគមន៍មូលដ្ឋានជាដំណើរការមួយដែលទាមទារពេលវេលា និងការជួយជ្រោមជ្រែងពីសំណាក់អ្នកពាក់ព័ន្ធនានា។

ប៉ុន្តែយើងឃើញថា ការអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិមិនត្រូវបានអនុវត្តឱ្យបានពេញលេញ ឬប្រកបដោយប្រសិទ្ធិភាពឡើយ។ អាជីវកម្មឈើខុសច្បាប់កើតឡើងនៅតំបន់ជាច្រើន ជាពិសេសនាភាគឦសាននៃប្រទេសមាន ខេត្តស្ទឹងត្រែងជាដើម។ ចំណែកឯបទល្មើសនេសាទវិញបានកើតឡើងស្ទើរពេញផ្ទៃប្រទេស។

ពេលខ្លះប្រជាជនសហគមន៍បានចំណាយធនធានផ្ទាល់ខ្លួន និងចូលរួមយ៉ាងសកម្មដើម្បីការពារនូវធនធានធម្មជាតិនៅក្នុងតំបន់គាត់ បើទោះបីជាគាត់មិនត្រូវបានច្បាប់អនុញ្ញាតឱ្យចាប់ជនល្មើស ឬផាកពិន័យក៏ដោយ។ មានករណីជាច្រើនដែលជនល្មើសត្រូវបានចាប់ខ្លួនដោយសហគមន៍សហការជាមួយអាជ្ញាធរមូលដ្ឋានបញ្ជូនមកកាន់មន្ទីរជំនាញ ហើយជនល្មើសនោះត្រូវបានដោះលែងបន្ទាប់ពីបានបង់ប្រាក់ទៅដល់មន្ត្រីជំនាញ។ ម្តងជាពីរដងនៃអំពើពុករលួយ និងមិនអនុវត្តច្បាប់ដូចនេះបានធ្វើឱ្យសហគមន៍ទទួលអារម្មណ៍ថាត្រូវបានគេបោកប្រាស់ដោយសារពួកគាត់ខំអភិរក្ស ដូចជាទុកឱ្យជនល្មើស និងមន្ត្រីពុករលួយប្រមូលផលទៅវិញ។





អន្លង់ត្រីដែលសំរាប់ឱ្យត្រីពងកូន និងជាជំរកត្រីមេពូជ ហើយដែលសហគមន៍ខិតខំថែរក្សានោះ បានក្លាយជាកន្លែងកើបលុយរបស់ជនល្មើសជាមួយនឹងអំពើពុករលួយរបស់មន្ត្រីជំនាញ។ ដូចគ្នាដែរសំរាប់តំបន់អភិរក្សក្នុងព្រៃរបស់សហគមន៍ដែលលាន់ឮមិនសូវដាច់នូវសំលេងរណារយន្ត។

តើឱ្យសហគមន៍បណ្តុះនូវស្មារតីអភិរក្សយ៉ាងដូចម្តេច ប្រសិនបើលទ្ធផលនៃការអភិរក្សរបស់គាត់ គឺការបញ្ឈឺចិត្តយ៉ាងគគ្លើនពីសំណាក់ជនល្មើស និងមន្ត្រីដែលជាអ្នកពង្រឹងច្បាប់នោះ?

តើឱ្យជនល្មើសខ្លាចរអារច្បាប់យ៉ាងដូចម្តេច ប្រសិនបើអ្នកអនុវត្តច្បាប់កំពុងមមាញឹកប្រមូលលុយពីជនល្មើសទាំងនោះដោយមិនខ្លាចក្រែងច្បាប់?

ដោយមិនបាញ់ឆ្ពោះទៅមន្ត្រីដែលល្អ មន្ត្រីខ្លះមិនមានឧត្តមគតិ ឬមនសិការជាតិឡើយ ដោយក្រុមនេះគិតតែប្រយោជន៍ផ្ទាល់ខ្លួន និងមិនគិតទៅដល់និរន្តរភាព ឬមហន្តរាយបរិស្ថាន និងសង្គមនោះឡើយ។ មន្ត្រីជំនាញដែលរាជរដ្ឋាភិបាលមានទំនុកចិត្ត និងបានផ្តល់តំណែងឱ្យ គួរណាស់តែយកចិត្តទុកបំរើដល់ប្រជាពលរដ្ឋ និងប្រយោជន៍សាធារណៈ។

ប្រជាពលរដ្ឋដែលខិតខំការពារធនធានធម្មជាតិ និងបរិស្ថានរបស់ប្រទេសខ្លួន គួរណាស់តែទទួលបាននូវការគាំទ្រពីសំណាក់អ្នកពាក់ព័ន្ធទាំងឡាយ ជាពិសេសមន្ត្រីជំនាញ។ រីឯមន្ត្រីដែលចូលរួមបំផ្លាញធនធានធម្មជាតិជាមួយជនល្មើស គួរតែត្រូវបានផ្តន្ទាទោសឱ្យបាន

# ក្រុមហ៊ុនដីសម្បទានពីរកំពុងយាយីការរស់នៅរបស់ប្រជាជន ឃុំអូរស្វាយ និងឃុំកោះស្នែង

ករណីសិក្សាដោយលោក កុប ម៉ាត់
ប្រធានបណ្ដាញសកម្មជនបរិស្ថាន

ប្រជាជននៅក្នុងឃុំអូរស្វាយ និងឃុំកោះស្នែងកំពុងប្រឈមមុខនឹងការបាត់បង់ដីស្រែចំការ និងព្រៃសហគមន៍របស់ខ្លួនដោយសារតែគម្រោងដីសម្បទានដែលរដ្ឋាភិបាលបានផ្ដល់ទៅឱ្យក្រុមហ៊ុន **ជីជីវើល** និងក្រុមហ៊ុន **ផលិតម្សៅដំឡូងមីចំកាត់**។

តាមការរៀបរាប់របស់អាជ្ញាធរមូលដ្ឋានបានឱ្យដឹងថា ភូមិដែលប៉ះពាល់ខ្លាំងជាងគេគឺភូមិអូរស្វាយ និងភូមិកោះព្នៅនៅក្នុងឃុំអូរស្វាយ និងភូមិកោះកីក្នុងឃុំកោះស្នែង។



**ការដ្ឋានស្តុកឈើរបស់ក្រុមហ៊ុនជីជីវើល** (GG World Group)



ព្រឹត្តិបត្រ ធម្មជាតិ និង ជីវិត មករា_កុម្ភៈ ២០០៨

នៅក្នុងឃុំអូរស្វាយមានប្រជាជនរស់នៅចំនួន ៤៩០ គ្រួសារ និងឃុំ កោះស្នែងមាន ៣៧៣ គ្រួសារក្នុងនោះភូមិកោះព្នៅមាន ៩២ គ្រួសារ ភូមិអូរស្វាយ ១៥៧ គ្រួសារ និងភូមិកោះកីចំនួន ៦៦ គ្រួសារ។

ប្រជាជននៅក្នុងភូមិកោះកី បានត្អូញត្អែរពីការបាត់បង់នូវធនធានធម្មជាតិដែលគាត់មាន ហើយពួកគាត់ព្រួយបារម្ភណ៍យ៉ាងខ្លាំងអំពីអនាគតរបស់សហគមន៍របស់គាត់ជាពិសេសពាក់ព័ន្ធទៅនឹងភាពគ្មានការងារធ្វើ និងគ្មានប្រាក់ចំណូលដោយសារធនធានធម្មជាតិរបស់ពួកគាត់ត្រូវបានទន្ទ្រាន និងបំផ្លាញដោយក្រុមហ៊ុនដីសម្បទានខាងលើ។ គាត់ក៏បានឱ្យដឹងដែរថា រហូតមកដល់ពេលនេះ គ្មានអ្នកភូមិកោះកីណាម្នាក់ត្រូវបានក្រុមហ៊ុនទាំងនោះផ្ដល់ការងារឱ្យធ្វើឡើយ។

មេភូមិកោះកី លោក ព្រុំ ស៊ី បានមានប្រសាសន៍ថា " ក្រុមហ៊ុនអាចយកដីពួកយើងបានគ្រប់ពេលពីព្រោះយើងគ្មានប័ណ្ណកម្មសិទ្ធិ ហើយបើសិនជាក្រុមហ៊ុនយកមែននោះ ប្រជាជនក្នុងភូមិនេះមិនដឹងជាត្រូវរស់នៅយ៉ាងដូចម្ដេចទេ បើគ្មានចំការ គ្មានព្រៃនោះ "។

ប្រជាជនក្នុងតំបន់នេះ ជាពិសេសក្នុងភូមិទាំង៣ដែលបានរៀបរាប់ខាងលើ ពឹងផ្អែកលើធនធានព្រៃឈើ ជាពិសេសអនុផលព្រៃឈើដូចជា ការប្រមូលជ័រគ្រប់ប្រភេទ បន្លែព្រៃ ផ្លែឈើព្រៃ ការរកឃ្មុំ ការបោចវល្លិ៍ ឬស្សី ដែលជាប្រភពចំណូលដ៏សំខាន់របស់ពួកគាត់រួមជាមួយនឹងការរកសត្វព្រៃដូចជា ត្រកួត និងជ្រូកព្រៃដែលត្រូវបានប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់ប្រជាជន។ នៅក្នុងតំបន់ព្រៃសហគមន៍ក៏មានដីស្រែ និងចំការរបស់ប្រជាជនផងដែរ។ ក្រៅពីនេះ ធនធានត្រីដែលជាប្រភពនៃចំណីអាហារ មិនអាចខ្វះបានសំរាប់ពួកគាត់គឺស្ថិតនៅតាមទន្លេ និងអូរដែលហូរកាត់តំបន់ព្រៃសហគមន៍។ ក្រៅពីការដកហូតធនធានធម្មជាតិ ពួកគាត់ក៏ជាក្រុមដែលមានឆន្ទះខ្ពស់ក្នុងការថែរក្សាធនធានទាំងនោះឱ្យមាននិរន្តរភាពផងដែរ ជាក់ស្ដែងប្រជាជនក្នុងឃុំនីមួយៗ បានរួមគ្នាបង្កើតជាសហគមន៍ព្រៃឈើផង និងសហគមន៍នេសាទផង។


ព្រៃឈើក្នុងតំបន់ក្រុមហ៊ុនម្សៅជំឡូងមីចំកាត់

**ក្រុមហ៊ុនផលិតម្សៅជំឡូងមីចំកាត់** បានទទួលការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី ១១ ខែវិច្ឆិកា ឆ្នាំ១៩៩៩ លើផ្ទៃដីចំនួន ៧៤០០ ហិចតាសំរាប់រយៈពេល ៧០ ឆ្នាំក្នុងគោលបំណង វិនិយោគដាំដើមម៉ៃសាក់។ ក្រុមហ៊ុននេះជាកម្មសិទ្ធិរបស់ជនជាតិខ្មែរឈ្មោះ **លោក កែវ វុទ្ធី**។ ទីតាំងភូមិសាស្ត្ររបស់ក្រុមហ៊ុននៅក្នុងស្រុកចំនួនពីរ គឺស្រុកស្ទឹងត្រែង និងស្រុកថាឡាបរិវ៉ាត់។ ក្រុមហ៊ុនបានបង់ប្រាក់កក់ដល់រដ្ឋាភិបាល និងកំពុងដំណើរការដាំដុះដើមម៉ៃសាក់លើផ្ទៃរបស់ខ្លួនបានតែមួយផ្នែកតូចប៉ុណ្ណោះចាប់ពីឆ្នាំ ១៩៩៩ មក។[១]

ក្រុមហ៊ុន **ជីជីវើល (GG World Group)** បានទទួលការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ លើផ្ទៃដីចំនួន ៥ ៤៩៣ ហិចតាសំរាប់រយៈពេល ៧០ ឆ្នាំក្នុងគោលបំណងវិនិយោគដាំដើមម៉ៃសាក់ ចន្ទគ្រឹះស្នា ឈើហូបផ្លែ និងបង្កើតរោងចក្រកែច្នៃ។ ក្រុមហ៊ុននេះមានថៅកែជាជនជាតិចិនឈ្មោះ **អាន យ៉ាំង យិន ឆាំង** ។ ចាប់ពីពេលចុះកិច្ចសន្យាឆ្នាំ២០០៥ រហូតមកដល់ឆ្នាំ២០០៧ ក្រុមហ៊ុននេះមិនទាន់បានបង់ប្រាក់កក់ជូនរដ្ឋនៅឡើយទេ។ ទីតាំងភូមិសាស្ត្ររបស់ក្រុមហ៊ុនស្ថិតនៅក្នុងឃុំសាមគ្គី ស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង គឺនៅតាមបណ្តោយផ្លូវជាតិលេខ៧ ពីស្ទឹងត្រែងទៅព្រំដែនឡាវ។[២]

តាមការជួបផ្ទាល់ជាមួយសហគមន៍មូលដ្ឋាន ការផ្តល់ដីសម្បទានឱ្យក្រុមហ៊ុននេះបានធ្វើឡើងដោយមិនមានការចូលរួមពីសំណាក់ប្រជាជនមូលដ្ឋានចូលរួមក្នុងការសំរេចចិត្តឡើយ។



ព្រឹត្តិបត្រ ធម្មជាតិ និង ជីវិត មករា_កុម្ភៈ ២០០៨

អ្នកភូមិអូរស្វាយបានឱ្យដឹងថា ពួកគាត់មិនដឹងថាដីព្រៃដ៏ក្រាស់ដែលពួកគាត់ធ្លាប់ចូលរកអនុផល និងផលព្រៃឈើក្នុងតំបន់នោះត្រូវបានគេផ្តល់ក្រុមហ៊ុនឯកជនពីពេលណានោះទេ ទើបតែនៅដើមឆ្នាំ២០០៥ មេភូមិអូរស្វាយ និងមេឃុំបានមកប្រាប់ពួកគាត់ថា ដីទាំងនោះត្រូវបានរដ្ឋប្រគល់ឱ្យក្រុមហ៊ុនឯកជនបាត់ទៅហើយ។

តាមព័ត៌មានទទួលបានពីការជួបសំភាសន៍ជាមួយប្រជាជននៅភូមិកោះកីដែលជាភូមិនៅជាប់នឹងក្រុមហ៊ុនជីជីវើលនេះបានឱ្យដឹងថា ដំបូងក្រុមហ៊ុនកាប់យកតែឈើប្រណិតៗដូចជាក្រញូង និងបេងយកទៅលក់ឱ្យឈ្មួញ បច្ចុប្បន្ននេះក្រុមហ៊ុនកំពុងកាប់ឈើមានតំលៃស្ទើរគ្រប់ប្រភេទ។ ការកាប់ឈើនោះធ្វើឡើងនៅពេលថ្ងៃ រួចដឹកយកមកទុកក្នុងការដ្ឋានរបស់ខ្លួនរហូតដល់ពេលយប់ស្ងាត់ទើបដឹកចេញទៅកាន់ទីរួមខេត្តស្ទឹងត្រែង។

តាមអត្ថបទព័ត៌មានរបស់កាសែតរស្មីកម្ពុជាបានឱ្យដឹងថា ចាប់តាំងពីធ្វើសកម្មភាពនៅឆ្នាំ២០០៥មក ក្រុមហ៊ុនជីជីវើល បានធ្វើសកម្មភាពឈូសឆាយ និងបានកាប់ឈើគ្រប់ប្រភេទនៅក្នុងតំបន់ដីសម្បទាននេះយកមកកែច្នៃ និងលក់នៅតាមទីផ្សារក្នុងប្រទេស ហើយសកម្មភាពទាំងនេះកំពុងបន្តយ៉ាងគគ្រឹកគគ្រេងនាពេលថ្មីៗនេះ។ អត្ថបទដដែលក៏បានឱ្យដឹងតាមរយៈសម្តីរបស់ មន្ត្រីកសិកម្មថា ចំពោះលទ្ធផលនៃការដាំដុះឡើងវិញរបស់ក្រុមហ៊ុនតាមកិច្ចសន្យានោះ គឺធ្វើបានតិចតួចបំផុត ហើយវាគ្មានគុណភាពទៀតផង។


ផ្ទៃដីដែលក្រុមហ៊ុន G G World Group បានកាប់ឆ្ការព្រៃរួច

សហគមន៍មូលដ្ឋាន បានឱ្យដឹងថា ការកាប់ដីសម្បទានរបស់ក្រុមហ៊ុន ជី ជី វើលគ្រប

និងក្រុមហ៊ុនម៉េង្វៀវជំឡួងមីចំកាត់ បានបំផ្លាញប្រភេទឈើមានតំលៃជាច្រើនប្រភេទ និងធ្វើឱ្យបាត់ជំរកសត្វព្រៃក្នុងតំបន់។ ការបាត់បង់ព្រៃឈើក៏បណ្តាលឱ្យពពួកជីវចំរុះជាច្រើនទៀតដែលធ្លាប់ពឹងអាស្រ័យលើព្រៃទាំងនោះត្រូវបាត់បង់។ ការកាប់បំផ្លាញព្រៃឈើក៏បណ្តាលឱ្យមានការកើនកំដៅក្នុងតំបន់ផងដែរ។ ពួកគាត់បានប្រាប់ថា នៅរដូវប្រាំងសីតុណ្ហភាពក្តៅជាងមុនដោយសារតែព្រៃឈើជាច្រើនត្រូវកាប់ និងដុតបំផ្លាញដោយក្រុមហ៊ុន។

ក្នុងចំនោមអ្នកភូមិ៦៦គ្រួសារក្នុងភូមិកោះកី មានតែ៧គ្រួសារតែប៉ុណ្ណោះដែលមិនមានដីកសិកម្មក្នុងតំបន់ដីសម្បទានរបស់ក្រុមហ៊ុននេះ។ ផ្ទៃដីកសិកម្មសរុបដែលស្ថិតក្នុងប្លង់សម្បទានមានចំនួនប្រមាណជាង១១២ហិចតា (ទិន្នន័យចុះវាស់វែងដោយមន្ទីរសុរិយោដីខេត្តស្ទឹងត្រែងជាមួយប្រជាជន)។ ប្រជាជនក្នុងភូមិបានឱ្យដឹងថា ពួកគាត់មិនត្រូវបានគេផ្តល់ឱ្យនូវប្លង់កម្មសិទ្ធិដីធ្លីលើផ្ទៃដីកសិកម្មដែលពួកគាត់កំពុងប្រកបរបរកសិកម្មនោះឡើយ ហើយក្រុមហ៊ុនក៏មិនអនុញ្ញាតឱ្យពួកគាត់ពង្រីកផ្ទៃដីកសិកម្មទៀតដែរ។ លើសពីនេះទៅទៀតក្រុមហ៊ុនបានចេញការណែនាំមិនឱ្យប្រជាជនដាំដំណាំដែលអាចប្រមូលផលក្នុងរយៈពេលយូរដូចជា ដូង ស្វាយ ខ្នុរ ឬក្រូចជាដើមឡើយ។

ក្រៅពីអនុផលព្រៃឈើ ប្រជាជននៅក្នុងឃុំទាំងពីរនេះពឹងផ្អែកលើការរកត្រីនៅតាមត្រពាំង និងអូរដែលនៅក្នុងតំបន់ព្រៃសហគមន៍សំរាប់ជាម្ហូបអាហារប្រចាំថ្ងៃ។ ប៉ុន្តែត្រពាំងនិងអូរដែលជាទីពំនឹងទាំងនោះ ត្រូវបានក្រុមហ៊ុនឈូសឆាយ និងចាក់លុបដែលបានធ្វើឱ្យពួកគាត់មានបញ្ហាក្នុងការរកម្ហូបប្រចាំថ្ងៃ។

ប្រភេទព្រៃនៅក្នុងព្រៃសហគមន៍មានព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះចំរុះ ព្រៃល្បោះ និងតំបន់ព្រៃដាំ និងតំបន់ខ្លះត្រូវបានក្លាយជាតំបន់ចំការ។ ចំពោះប្រភេទឈើវិញមានដូចជា បេង ធ្នង់ នាងនួន សុក្រម កកោះ ត្រាច ពពេល ខ្លុង រាំងភ្នំ និងឈើទាល។ ក្នុងតំបន់ព្រៃសហគមន៍នេះក៏សំបូរទៅដោយសត្វស្លាបជាច្រើនប្រភេទដូចជា កេងកងធំ



ព្រឹត្តិបត្រ ធម្មជាតិ និង ជីវិត មករា_កុម្ភៈ ២០០៨

សត្វករស ស្តេចកុលីត មាន់ទោពណ៌ប្រាក់ អំបូរត្មាត ត្រដក់តូច ញ៉ាំង សេកអាត់ សារិកាកែវវែងលលកបាយ ពពូល និងអំបូរត្រសេះ។ ចំណែកថនិកសត្វវិញមានដូចជា ឈ្លូស ខ្ទីង ជ្រូកព្រៃ ទន្សោង ប្រើស កាំប្រមា៉ ទោចថ្កាល់លឿង រញ្ជី ប្រម៉ោញ ភេ ស្វាកន្ទុយស ស្វាអង្កត់ ស្វាក្រវ៉ាត់ អំបូរស្រពោច និងអំបូរខ្លា ដូចជាខ្លាពពក ខ្លាលឿងមាស ឆ្មាដាវ និងពពួកល្មូនមានពស់ ត្រកួត អណ្តើក អន្សង ពង្រូល.... ។ល។[៣]

គួររំលឹកដែរថា ចាប់តាំងពីដើមទសវត្ស១៩៩០មករដ្ឋាភិបាលកម្ពុជាបានផ្តល់ដីដែលមានទំហំធំៗដល់ក្រុមហ៊ុនឯកជនដើម្បីអភិវឌ្ឍដំណាំឈើដាំ និងកសិកម្មក្នុងទ្រង់ទ្រាយធំ។ រហូតមកដល់ឆ្នាំ២០០៧ ផ្ទៃដីចំនួន ៩៤៣ ០៦៩ ហិចតាត្រូវបានផ្តល់ជូនក្រុមហ៊ុនឯកជនដែលមានទីតាំងស្ទើរគ្រប់ខេត្តក្រុងក្នុងប្រទេស។ ការផ្តល់ដីសម្បទាននេះបាន និងកំពុងធ្វើឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន និងសេដ្ឋកិច្ច-សង្គមរបស់សហគមន៍ជនបទ។ ក្នុងចំណោមខេត្តក្រុងដែលមានផ្ទៃដីសម្បទាន ខេត្តស្ទឹងត្រែងមានផ្ទៃដីសម្បទានសេដ្ឋកិច្ច ធំជាងគេរហូតដល់ ១៧៩ ៨៩៩ ហិចតា (ប្រភពៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ គិតមកដល់ថ្ងៃ៣១ ធ្នូ ២០០៦) និងមានក្រុមហ៊ុនចំនួន ១០ កំពុងដំណើរការ។

**********************

[១] តំណាងពិសេសលោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា (ខែ មិថុនា ២០០៧) សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្ស។

[២] តំណាងពិសេសលោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំប្រទេសកម្ពុជា (ខែ មិថុនា ២០០៧) សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្ស។

[៣] ការប៉ាន់ស្មានលើធនធានធម្មជាតិដោយមានការចូលរួម- អង្គការសេប៉ា ឆ្នាំ ២០០០

# ភូមិ កងណាក ប្រឈមមុខការបាត់បង់របបនៃការចិញ្ចឹមជីវិត

អត្ថបទដោយលោក រស់ បណ្ឌុស



**ភូមិដ្ឋានរបស់ប្រជាជននៅភូមិ កងណាក**

កងណាក គឺជាភូមិមួយ ដែលស្ថិតនៅក្នុងឃុំវ៉ឺនសៃ ស្រុកវ៉ឺនសៃ ខេត្តរតនគិរី ភាគឦសាននៃប្រទេសកម្ពុជា។ ភូមិនេះមានប្រជាជនសរុបចំនួន៧៨គ្រួសារ ដែលស្មើនឹង៥៨១នាក់។ ប្រជាជនទាំងអស់នៅក្នុងភូមិនេះ សុទ្ធសឹងជាជនជាតិដើមភាគតិច មានជនជាតិកាវ៉ែតចំនួន៥៧៤នាក់ (៩៨.៨%) ជនជាតិព្រៅចំនួន ៤នាក់ (0.៨%)





ជនជាតិគ្រឹងចំនួន១នាក់ (0.២%) និងជនជាតិចារាយចំនួន១នាក់ (0.២%)។

ដំបូងឡើយប្រជាជនទាំងអស់នៅក្នុងភូមិនេះ សុទ្ធតែជាជនជាតិកាវ៉ែតទាំងអស់ ប៉ុន្តែក្រោយមកដោយសារប្រជាជនមួយចំនួនតូចបានភ្ជាប់ទំនាក់ទំនងរៀបការជាមួយជនជាតិគ្រឹង ចារាយ និងព្រៅ ដូចនេះធ្វើឱ្យប្រភេទជនជាតិដើមភាគតិចដែលមករស់នៅក្នុងភូមិនេះឡើងដល់៤ប្រភេទផ្សេងៗគ្នា។ សូមបញ្ជាក់ថាភាសានិយាយរបស់ជនជាតិទាំង៤ប្រភេទនេះ អាចទំនាក់ទំនងគ្នាបាន។

ធនធានធម្មជាតិ មានសារៈសំខាន់ណាស់ សម្រាប់ការរស់នៅ របស់ប្រជាជនភូមិកងណាក។ លោក ឃឿច ប៉ែវ អាយុ៥២ឆ្នាំ និងជាប្រធានភូមិកងណាក បាននិយាយថា "ប្រជាជនភូមិកងណាកប្រកបរបរចិញ្ចឹមជីវិតដោយការធ្វើស្រែចំការ ត្បាញកាផា ចង្អេរ ល្អី រកសត្វ រកជ័រទឹក ចិញ្ចឹមសត្វ និងរកត្រីបន្តិចបន្តួច។ មុខរបរទាំងនេះមានទំនាក់ទំនងយ៉ាងជិតស្និតទៅនឹងធនធានធម្មជាតិ ពិសេសធនធានព្រៃឈើក្នុងតំបន់។

ការត្បាញកាផា ចង្អេរ ល្អី ជាមុខរបរមួយដែលជួយដល់ជីវភាពការរស់នៅរបស់ប្រជាជនភូមិកងណាក ក្នុងករណីធ្វើស្រូវមិនបានដោយគ្រោះធម្មជាតិ ឬសត្វបំផ្លាញ។ ដើម្បីធ្វើសម្ភារៈទាំងនេះបាន គេត្រូវការវត្ថុធាតុដើមមួយចំនួនដូចជាផ្អេរ ផ្ដៅ ឬស្សី ដែលអាចរកបានពីតំបន់ព្រៃជុំវិញភូមិ ហើយផលិតផលដែលពួកផលិតបានយកទៅលក់នៅទីផ្សារ វ៉ឺនសៃ ក្នុងតំលៃចន្លោះពី ៥000 ទៅ ១0,000រៀល ទៅតាមទំហំសម្ភារៈ ។ ផ្សារនេះមានចម្ងាយប្រមាណ៤ គីឡូម៉ែត្រពីភូមិរបស់ពួកគាត់។

ជាមួយគ្នានេះដែរ មុខរបរបណ្ដើរឆ្កែចាប់សត្វនៅតាមព្រៃភ្នំ ក៏ជួយមួយផ្នែកផងដែរដល់ជីវភាពរស់នៅរបស់ប្រជាជនភូមិកងណាក។ កន្លងមកនេះ ពួកគាត់ធ្លាប់

ចាប់បានច្រើននូវប្រភេទសត្វអណ្តើក ត្រកួត និងជ្រូកព្រៃ ចំណែកប្រភេទសត្វផ្សេងទៀតដូចជាពស់វែក និងពង្រូល កំររកបានណាស់សម្រាប់ប្រជាជនធម្មតា។ ដើម្បីចាប់សត្វនេះបាន ត្រូវដឹងពីបែបបទជាច្រើនទាក់ទងនឹងជីវសាស្ត្ររបស់សត្វនោះ ហើយនៅក្នុងភូមិកងណេក មានមនុស្សតែ២នាក់ប៉ុណ្ណោះដែលមានជំនាញនេះ ។ នៅលើទីផ្សាររ៉ុនសៃ ត្រកួត ១គ.ក មានតំលៃ ១៥,០០០រៀល អណ្តើក ១ គ.ក មានតំលៃ ១៧,០០០-១៨,០០០រៀល ពស់វែក ១ គ.ក មានតំលៃ ១២៥,០០០រៀល និងពង្រូល ១ គ.ក មានតំលៃ ២០០,០០០រៀល។

ការដងជ័រទឹក ជាមុខរបរគួបផ្សំសំខាន់មួយទៀតក្នុងការផ្គត់ផ្គង់ជីវភាពរស់នៅរបស់គ្រួសារអ្នកភូមិកងណេក។ រហូតមកដល់ពេលបច្ចុប្បន្ននេះ ស្ទើរគ្រប់គ្រួសារទាំងអស់ក្នុងភូមិកងណេក សុទ្ធតែមានដើមច្បោះជ័រ (ដើមឈើទាល និងត្រាច) ដែលក្នុងនោះមួយគ្រួសារមានដើមច្បោះជ័រតិចបំផុតពី ២០-៣០ដើម និងច្រើនបំផុតរហូតដល់ទៅ ៥០-១០០ ដើម។ ដើមច្បោះជ័រទាំងនោះ ស្ថិតនៅក្នុងព្រៃចម្ងាយ ប្រមាណពី ១០ ទៅ ១៥ គីឡូម៉ែត្រពីភូមិ នឹងចំណាយរយៈពេលធ្វើដំណើរដោយថ្មើជើងចំនួន ៣ម៉ោង។ ក្នុង១កាននៃជ័រទឹក ប្រជាជនអាចលក់បានប្រាក់ចំនួន ៣០,០០០រៀល នៅផ្សាររ៉ុនសៃ ហើយជាទូទៅ ប្រជាជនក្នុងមួយលើកអាចរកជ័របានពី ១ ទៅ ៣ កានទើបយកទៅលក់ម្តង។ មុខរបររកជ័រនេះ គឺធ្វើតែនៅពេលទំនេរ ពិសេសសម្រាប់តម្រូវការបរិភោគប្រចាំថ្ងៃ។

ការងារទាំងបីនេះ មានទំនាក់ទំនងផ្ទាល់ជាមួយនឹងធនធានព្រៃឈើ ចំណែកមុខរបរផ្សេងទៀតដូចជាការធ្វើស្រែចំការ នេសាទ ដាំបន្លែ និងចិញ្ចឹមសត្វក៏មាន



ព្រឹត្តិបត្រ ធម្មជាតិ និង ជីវិត មករា-កុម្ភៈ ២០០៨

ទំនាក់ទំនងដោយប្រយោលជាមួយធនធានព្រៃឈើ។ ជាការពិត ស្រែរបស់បងប្អូនជនជាតិការ៉ែត មានរបងឈើព័ទ្ធជុំវិញដើម្បីការពារពីការបំផ្លាញពីសំណាក់សត្វគោ និងក្របី។ ដូចគ្នានេះដែរ ការចិញ្ចឹមសត្វ នេសាទត្រី និងដាំ បន្លែ ក៏ត្រូវការធនធានព្រៃឈើផងដែរ ដូចជាឈើសម្រាប់ធ្វើក្រោល អនុផលព្រៃឈើសម្រាប់ធ្វើឧបករណ៍នេសាទត្រី ផ្តើសម្រាប់ដាំបន្លែ។ល។

មុខរបរដែលរៀបរាប់ខាងលើនេះ នឹងអាចទទួលរកផលប៉ះពាល់ពីគំរោងវិនិយោគដីដើម្បីដាំកៅស៊ូ ដែលប្រជាជននៅទីនោះបានឮដំណឹងនេះ ហើយពួកគាត់កំពុងតែមានក្តីបារម្ភណ៏នៅក្នុងចិត្ត ។

លោក កាត អ អាយុ៤៥ឆ្នាំ ដែលជាប្រធានសហគមន៏ព្រៃ ឈើ បាននិយាយក្នុងភាពមិនសូវច្បាស់លាស់ថា មានគេចង់មកវិនិយោគដីនៅក្នុងតំបន់ដីសហគមន៏របស់គាត់ដាំដើមកៅស៊ូ។

លោកប្រធានភូមិ ឃឿច ប៉ែវ ក៏បាននិយាយដូចគ្នានេះដែរថា គាត់ត្រូវបានខាងក្រុមប្រឹក្សា ឃុំអញ្ជើញឱ្យចូលរួមប្រជុំអំពីបញ្ហាវិនិយោគដីនេះដែរ ។ លោកបន្តថា ឃុំបានសុំយោបល់ពីអ្នកតំណាងភូមិចំនួនប្រាំទាក់ទងនឹងវត្តមានរបស់ក្រុមហ៊ុន និងការអភិវឌ្ឍក្នុងតំបន់ ហើយបានស្នើឱ្យចុះហត្ថលេខាគាំទ្រប្រសិនបើយល់ព្រមទទួលយកក្រុមហ៊ុននោះ។

លោក ឃឿច ប៉ែវ មានប្រសាសន៏ "ទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនព្រមដែរពីព្រោះតាំងពីដូនពីតាមកមិនដែលឃើញនរណាគេមកបង្កើតក្រុមហ៊ុនអញ្ចឹងទេ។ ខ្ញុំចង់ទុកព្រៃទាំងអស់នេះឱ្យនៅបែបនេះដើម្បីអារក្ស និងអ្នកតាឱ្យដូចពីសង្គមតែ

ម្តង។ ប្រសិនបើឱ្យព្រៃទាំងនោះទៅគេ ព្រៃអារក្សនឹងរលាយហិនហោចអស់"។

លោក កាត អ គាំទ្រមតិលោកមេភូមិ ហើយលោកបានបន្ថែមថា "យើងចង់គ្រប់គ្រងព្រៃឈើទាំងនេះឱ្យមាននិរន្តរភាពទុកសម្រាប់ឱ្យកូនចៅជំនាន់ក្រោយ។ ព្រៃឈើទាំងនេះជាអាយុជីវិតរបស់បងប្អូនជនជាតិដើមភាគតិចការ៉ែត ហើយយើងចង់រស់នៅដោយមានធម្មជាតិនៅជាមួយទុកចិញ្ចឹមជីវិត និងសែនព្រេន"។



**ទិដ្ឋភាពនៃការរស់នៅផ្សារភ្ជាប់ជាមួយធម្មជាតិរបស់ជនអន្តោគ្រាម**



ព្រឹត្តិបត្រ ធម្មជាតិ និង ជីវិត មករា_កុម្ភៈ ២០០៨

# អ្វីខ្លះដែលបណ្តាលចិត្តអ្នកឱ្យមកកំសាន្ត នៅសហគមន៍ទេសចរណ៍បូរីអូរស្វាយ?

សហគមន៍ទេសចរណ៍ធម្មជាតិបូរីអូរស្វាយ បានចងក្រងឡើងក្រោមការសម្របសម្រួលរបស់សមាគមថែរក្សាបរិស្ថាន និងវប្បធម៌ ក្រោមការឧបត្ថម្ភ និងសហការពីក្រសួងទេសចរណ៍ និងមានការចូលរួមយ៉ាងសស្រាក់សស្រាំពីសហគមន៍ព្រៃឈើ សហគមន៍នេសាទបូរីអូរស្វាយ និងប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំអូរស្វាយ។

សហគមន៍ទេសចរណ៍ធម្មជាតិនេះបានបង្កើតឡើងក្នុងគោលបំណងបង្កើនប្រាក់ចំណូលបន្ថែមដល់សហគមន៍ដែលរស់ក្នុងឃុំអូរស្វាយតាមរយៈឧស្សាហកម្មគ្មានផ្សែង-ទេសចរណ៍ធម្មជាតិដែលមិនប៉ះពាល់ដល់បរិស្ថាន និងមាននិរន្តរភាពហើយដើរស្របនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។



**ផ្លូវចូលទៅកាន់បូរីអូរស្វាយដែលអមដោយរុក្ខជាតិ**

បូរីអូរស្វាយជាភូមិមួយដែលមានទីតាំងស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គក្បែរព្រំដែនកម្ពុជា និងឡាវ។ បូរីនេះកើតឡើងនៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៦៤ ដោយសារស្នាព្រះហស្តរបស់សម្តេច **នរោត្តម សីហនុ** ដែលព្រះអង្គបានបញ្ជូនទាហានស្ម័គ្រចិត្តចំនួន ១៩ នាក់មករស់នៅភូមិនោះក្នុងគោលបំណងដើម្បីថែរក្សា និងការពារព្រំដែនរបស់ប្រទេស

កម្ពុជា ។ ភូមិនេះត្រូវបានគេដាក់ឈ្មោះថា " ភូមិអូរស្វាយ " ដោយសារកាលពីមុន នៅក្នុងភូមិនេះមានដើមស្វាយធំៗជាច្រើនដុះនៅតាមមាត់ទន្លេ។ កត្តានេះហើយទើបធ្វើប្រជាជននៅ ក្នុងភូមិបានសំរេចចិត្តដាក់ឈ្មោះឱ្យភូមិនេះថា ភូមិអូរស្វាយ ហើយការដែលយើងហៅថា " បូរីអូរស្វាយ " នេះគឺ ដោយសារភូមិនេះបង្កើតឡើងដោយព្រះបញ្ញាញាណដ៏ឈ្លាសវៃរបស់ **ព្រះមហាក្សត្រ សីហនុ** ទើបព្រះអង្គប្រសិទ្ធនាមភូមិនេះថា "**បូរីអូរស្វាយ** "។ ក្នុងឃុំ អូរស្វាយមានភូមិចំនួន ៥ ក្នុងនោះមានភូមិកោះព្នៅ ភូមិអូរស្វាយ ភូមិអូររុន ភូមិកោះហិប និងភូមិរ៉ុនសៀន ។

ទន្លេមេគង្គភាគខាងលើនៃខេត្តស្ទឹងត្រែង ជាផ្លូវទឹកដែលប្រៀបបានទៅនឹងសរសៃឈាមដែលរត់ចុះឡើងរួមជាមួយអន្លង់ទឹកជ្រៅៗ ព្រៃលិចទឹក កោះ អូរ សុទ្ធតែជាទីជំរក និងកន្លែងពងកូនយ៉ាងសំខាន់របស់ប្រភេទត្រីមេពូជធំៗ សត្វផ្សោត និងសត្វស្លាបជាច្រើនប្រភេទទៀត ជាពិសេសមនុស្សជាច្រើននាក់បានពឹងអាស្រ័យជាមួយនឹងជីវៈចម្រុះទាំងនេះ។

តើអ្វីខ្លះដែលលោកអ្នកអាចកំសាន្តអារម្មណ៍នៅតំបន់សហគមន៍ទេសចរណ៍ធម្មជាតិបូរីអូរស្វាយ?

## តំបន់ព្រៃឈើសហគមន៍


ព្រៃឈើដ៏ស្តុកស្តម្ភរបស់សហគមន៍

ព្រៃឈើសហគមន៍មានទំហំប្រមាណ ៣២០០ ហិចតា និងចែកចេញជា ប្រភេទព្រៃពាក់កណ្តាលស្រោង ព្រៃល្បោះចំរុះ ព្រៃល្បោះ និង តំបន់ព្រៃដាំ និងតំបន់ចំការ។ តំបន់ព្រៃនេះសំបូរទៅដោយធនធានធម្មជាតិ អនុផលព្រៃឈើ និងជាជំរករបស់សត្វជាច្រើនប្រភេទ។



ព្រឹត្តិបត្រ ធម្មជាតិ និង ជីវិត មករា_កុម្ភៈ ២០០៨

ប្រជាជនក្នុងតំបន់នេះពឹងផ្អែកលើធនធានព្រៃឈើ ជាពិសេសអនុផលព្រៃឈើ ដូចជាការប្រមូលជ័រគ្រប់ប្រភេទ បន្លែព្រៃ ផ្លែឈើព្រៃ ការរកឃ្មុំ ការបោចវល្លិ៍ ឬស្សី ដែលជាប្រភពចំណូលដ៏សំខាន់របស់ពួកគាត់ រួមជាមួយនឹងការរកសត្វព្រៃដូចជា ត្រកួត និងជ្រូកព្រៃ ដែលត្រូវបានប្រើប្រាស់ជាលក្ខណៈប្រពៃណីរបស់ប្រជាជន។

នៅក្នុងព្រៃសហគមន៍សំបូរដោយដើមឈើជាច្រើនប្រភេទដូចជាបេង ធ្នង់ នាងនួន សុក្រម កកោះ ចង្រៃ ត្រាច ពពេល ខ្លុង រាំងភ្នំ ឈើទាល។ល។

### ភ្នំប្រាក់

ភ្នំប្រាក់ស្ថិតនៅក្នុងតំបន់ព្រៃរបស់សហគមន៍ និងពោរពេញទៅដោយសីលាដែលរលោបរលោងដោយពណ៌ប្រាក់។ តំបន់នេះជាអតីតកន្លែងដែលពួកបារាំងផលិតកាក់ប្រាក់នាសម័យអាណានិគមបារាំងដែលគេអោចឃើញសំណល់អណ្តូងរ៉ែនាពេលបច្ចុប្បន្ន។ នៅក្បែរភ្នំនេះមានស្ទឹងមួយដែលជាទីមនោរម្យសំរាប់ងូតលេងកំសាន្ត។

### ភ្នំផង្កោ

ស្ថិតនៅក្នុងតំបន់ព្រៃសហគមន៍ ភ្នំនេះមានកំពស់ប្រមាណ ៨០ ម៉ែត្រ។ ពីលើភ្នំនេះយើងអាចមើលឃើញនូវទិដ្ឋភាពដ៏ល្អត្រកាលនៃទន្លេមេគង្គ និងទេសភាពព្រៃឈើបៃតងខ្ចីដែលលាតសន្ធឹងដាច់កន្ទុយភ្នែក។

អ្នកដំណើរអាចសំរាន្តកំសានក្រោមម្លប់ត្រឈឹងត្រឈៃរបស់ដើមឈើដើម្បីស្រូបយកនូវខ្យល់អុកស៊ីសែនបរិសុទ្ធ ដែលមិនលាយឡំជាមួយសារធាតុពុលដូចនៅតំបន់ទីក្រុង។

### ព្រៃលិចទឹក

តាមបណ្តោយដងទន្លេមេគង្គ តំបន់ដីសើមរ៉ាមសារលាតសន្ធឹងប្រមាណ ៧គីឡូម៉ែត្រ ពីទីរួមខេត្តស្ទឹងត្រែង រហូតដល់ ៣ គីឡូម៉ែត្រពីព្រំដែនប្រទេសឡាវ។ ក្នុងតំបន់ដីសើមនេះ សំបូរពោរពេញទៅដោយព្រៃលិចទឹកឈរបង្អួតរាង ទាំងរដូវប្រាំង និងរដូវវស្សា។ នារដូវប្រាំង


ឫសរបស់ដើមឈើលិចទឹក

ដើមឈើលិចទឹកទាំងនោះបង្ហាញនូវឫសដ៏រឹងមាំរបស់គេ ដែលអាចយកឈ្នះលើកំលាំងទឹកហូរដ៏ខ្លាំងរបស់ទន្លេមេគង្គ និងជាកន្លែងដ៏ល្អបំផុតសំរាប់ជំរកត្រីពងកូននារដូវវស្សា។

ទិដ្ឋភាពព្រៃលិចទឹកដ៏ស្រស់ត្រកាល និងគួរឱ្យស្ញប់ស្ញែងនៃស្នាដៃស្ថាបត្យកម្មរបស់ធម្មជាតិនៅតំបន់នេះមិនងាយនឹងអាចរកបាននៅកន្លែងដទៃទៀតនៅលើពិភពលោក។

## ស្ទឹង និងអូរ

ទន្លេមេគង្គបានបង្កើតឱ្យមានស្ទឹង និងអូរជាច្រើននៅក្នុងតំបន់សហគមន៍ទេសចរណ៍ធម្មជាតិបូរីអូរស្វាយ។ ស្ទឹង និងអូរទាំងនេះបានបង្កើតឡើងនូវប្រព័ន្ធជីវៈចំរុះដ៏សំបូរបែប។

នៅទីនេះ យើងអាចប្រទះឃើញសត្វស្លាបជាច្រើនប្រភេទដូចជា កេងកងធំ សត្វករស ស្តេចកុលិត មាន់ទោពណ៌ប្រាក់ អំបូរត្មាត ត្រដក់តូច ព្រាំង សេកអាត់ សារិកាកែវវែង លលកបាយ ពពូល និងអំបូរត្រសេះ។

សំលេងទឹកហូរ រួមផ្សំនឹងសំលេងសត្វស្លាបដែលបន្លឺល្វើយៗ ធ្វើឱ្យអារម្មណ៍យើងស្រាកស្រាន្តនូវភាពហត់នឿយ ភាពតានតឹង និងធ្វើឱ្យអារម្មណ៍របស់យើងលង់លក់នៅក្នុងធម្មជាតិដែលគ្មានគូរប្រៀប។

## ទឹកជួរនៅតាមដងទន្លេមេគង្គ

ទន្លេមេគង្គបានបង្កើតនូវកោះតូចៗ និងទឹកជួរជាច្រើនកន្លែង។ ទឹកជួរជាទឹកដែលហូរបោកផ្ទប់ទៅនឹងជួរថ្មនៅក្នុងទន្លេ ឬនៅបាតក្រោមទន្លេ។ នៅតាមទឹកជួរមានប្រភេទត្រី និងសិប្បីសត្វមួយចំនួន រស់នៅដូចជា ត្រីក្អែក ត្រីកញ្ជ្រូកកន្ទុយក្រហម ត្រីក្របី ត្រីរៀល ត្រីចង្វាស្លឹកឫស្សី ត្រីខ្ទីង ត្រីក្រាយ ត្រីអាចម៍កុក ត្រីសណ្តាយ ត្រីខ្យា ត្រីប្រា ត្រីឆ្លាំង ដែលនេសាទបាន





ដោយប្រើមង សំណាញ់ (មីនា-ឧសភា) ឈ្នាងត្រាំ (កក្កដា-សីហា) ឈ្នាងជញ្ជាត់ (កញ្ញា-តុលា) សន្ទូចរនង លប ចាន់ (កក្កដា-ធ្នូ)។ ក្រៅពីនេះមានសត្វមាន់ទឹក ត្រចៀកកាំ ក្អែកទឹក ត្រដេវវិច កុក ចាប់ បង្កួយ និងថ្លែន។

បន្ថែមពីនេះ ប្រជាជនតែងនាំគ្នាទៅជីក ឬបាចចង្រិត និងសត្វម៉េងខាល្យួន (ភាសាតំបន់)តាមឆ្នេរខ្សាច់អែបនឹងជួរ ចាប់ពីខែធ្នូ-ខែមករា។ ចំណែកចាប់ពីខែមីនា-ខែមេសា គេនាំគ្នាទៅរាវខ្ចៅ ខ្យង ក្តាម និងកំពិស និងបេះត្រួយ និងផ្កាទន្សា ផ្ការំដេង ផ្លែសណ្តាន់ ត្រួយរាំង ដើមជន្ទល់ភ្នំសំរាប់ធ្វើ ជាបន្លែ និងប្រមូលគ្រួស ថ្មតូច ធំ ខ្សាច់គ្រើម។ល។

អ្នកទេសចរណ៍នឹងទទួលអារម្មណ៍រីករាយប្លែកជាមួយនឹងការចូលរួមក្នុងសកម្មភាពដែលបានរៀបរាប់ខាងលើ។

## ឆ្នេរទន្លេ

ខ្សាច់សស្អាតដែលមិនចាញ់ឆ្នេរសមុទ្រនាទីក្រុងព្រះសីហនុនោះ ជាទីដែលយើងអាចកំសាន្តអារម្មណ៍ជាមួយនឹងទឹកថ្លាឈ្វេងនៃទន្លេមេគង្គ នារដូវទឹកស្រក។

អ្នកនឹងមិនមានអារម្មណ៍នឿយណាយទាល់តែសោះជាមួយនឹងទិដ្ឋភាព និងទេសភាពទាំងនេះ។

## សត្វផ្សោត

ព្រំដែនកម្ពុជា និងឡាវស្ថិតនៅប្រមាណ ៧គីឡូម៉ែត្រពីបូរីអូរស្វាយ ដែលអាចធ្វើដំណើរតាមផ្លូវគោក ឬផ្លូវទឹក។ នៅតាមដងទន្លេមេគង្គក្បែរព្រំដែននោះ មានអន្លង់ធំមួយដែលជាជំរករបស់ត្រីផ្សោតប្រមាណ១០ក្បាល។

នៅទីនេះ យើងអាចមុជទឹកលេងកំសាន្ត និងអាចគន់មើលត្រីផ្សោតទឹកសាប។

## ត្រី

ការស្រាវជ្រាវរបស់គម្រោងសាលាភូមិបានឱ្យដឹងថា នៅក្នុងតំបន់នេះមានត្រីចំនួន



ការរកត្រីរបស់ប្រជាជននៅតាមទន្លេមេគង្គខេត្តស្ទឹងត្រែង

១៣០ ប្រភេទ និងសំបូរពោរពេញទៅដោយធនធានមច្ឆជាតិផ្សេងទៀត។

អ្នកទេសចរណ៍ដែលមកកាន់តំបន់នេះនឹងបានឃើញស្គាល់ ឬភ្លក្សរសជាតិនូវត្រីដែលមានឱជារសល្អប្លែកជាពិសេស ត្រីដែលជានិមិត្តសញ្ញានៃខេត្តស្ទឹងត្រែង គឺត្រីប៉ាសុីអុី។

ប្រសិនបើភ្ញៀវទេសចរណ៍ចង់កំសាន្តអារម្មណ៍ជាមួយនឹងការនេសាទត្រី ឬជិះទូកលេងកំសាន្តនោះ បូរីអូរស្វាយនឹងជាកន្លែងដែលលោកអ្នកមិនត្រូវមើលរំលងឡើយ។

**អ្នកជាអ្នកការពារបរិស្ថាន និងចូលរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍**

ក្រៅពីការយល់ដឹងពីការរស់នៅរបស់ប្រជាជន មូលដ្ឋានដែលរស់នៅពឹងផ្អែកលើធនធានធម្មជាតិ អ្នកនឹងត្រូវបានទទួលតំលៃជាអ្នកការពារបរិស្ថាន និងធម្មជាតិក៏ដូចជាការចូលរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។

ការបរិច្ចាគធនធាន និងពេលវេលារបស់លោកអ្នកនិងក្លាយជាការលើកទឹកចិត្តដ៏ធំធេងដល់សហគមន៍ និងសកម្មជនបរិស្ថានដែលបានព្យាយាមអភិរក្ស និងស្តារឡើងវិញនូវបរិស្ថាន ធនធានធម្មជាតិ ដើម្បីធានាឱ្យបាននូវនិរន្តរភាពសំរាប់កូនចៅជំនាន់ក្រោយ។

គួរបញ្ជាក់ផងដែរថា ខេត្តស្ទឹងត្រែងជាខេត្តមួយដែលដាច់ស្រយាលជាងគេបន្ទាប់ពីខេត្តរតនគីរី បើប្រៀបធៀបទៅនឹងខេត្តផ្សេងៗទៀត ហើយជាតំបន់មួយដែលមានជនជាតិភាគតិចរស់នៅចំរុះគ្នាចំនួន ១៩ ជនជាតិ។ ពិតមែនតែខេត្តនេះជាខេត្តមួយដែលពីមុនមិនសូវ





មានការចាប់អារម្មណ៍ ប៉ុន្តែដោយសារតែមានការអភិវឌ្ឍនូវវិស័យជាច្រើនដូចជា ហេដ្ឋារចនា-សម្ព័ន្ធ សន្តិសុខ និងសុវត្ថិភាពសង្គម នាពេលបច្ចុប្បន្ននេះ ខេត្តស្ទឹងត្រែងបានក្លាយទៅជាខេត្តមួយដែលចាប់ផ្តើមរីកមុខមាត់ខ្លាំង និងទទួលការចាប់អារម្មណ៍ខ្លាំងពីភ្ញៀវទេសចរគ្រប់មជ្ឈដ្ឋាន ទាំងភ្ញៀវជាតិ និងអន្តរជាតិ។

សមាគមថែរក្សាបរិស្ថាន និងវប្បធម៌សូមស្វាគមន៍ភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិទាំងឡាយដែលមានបំណងចង់ទស្សនាសហគមន៍ទេសចរណ៍ធម្មជាតិបូរីអូរស្វាយ។





# អត្ថបទដកស្រង់

## ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ប្រទេសកម្ពុជាបានដាក់ប្រើប្រាស់ជាលើកដំបូងនូវពាក្យ **ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន** (EIAs) នៅក្នុងឆ្នាំ១៩៩៥។ ទោះជាយ៉ាងណាក៏ដោយ រយៈពេលជាង១០ឆ្នាំកន្លងមកនេះ បទពិសោធនដាក់ស្តែងក្នុងផ្នែកនេះនៅមានកម្រិតកំណត់នៅឡើយ។ មានការលំបាកមួយចំនួនដែលរដ្ឋាភិបាលកំពុងប្រឈមនៅក្នុងដំណើរការរៀបចំចាត់ចែងជម្រុះ និងពិនិត្យរបាយការណ៍ EIA។

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងគ្រប់គ្រងធនធានធម្មជាតិ (ដែលបានអនុម័តនៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៦) ចែងថា ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលើរាល់គម្រោង និងសកម្មភាពទាំងអស់។ ទោះជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលយល់ថា ការធ្វើបែបនេះត្រូវការពេលវេលាច្រើនណាស់។

អាស្រ័យហេតុនេះ រដ្ឋាភិបាលបានអនុម័តអនុក្រឹត្យមួយ ស្តីពីដំណើរការ EIA ដោយភ្ជាប់ជាមួយនូវតារាងឧបសម្ព័ន្ធ ស្តីពីប្រភេទ និងទំហំគម្រោងដែលត្រូវដាក់ឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (EIA) និង/រឺគម្រោងដែលត្រូវដាក់ឱ្យធ្វើការវាយតម្លៃ EIA។ សកម្មភាពទាំងអស់ដែលរួមបញ្ចូលនៅក្នុងតារាងឧបសម្ព័ន្ធនោះ គឺជាបណ្តាសកម្មភាពដែលអាចបង្កជាការគំរាមកំហែងចំពោះបរិស្ថាន និងត្រូវបានចែកចេញជាក្រុមខុសៗគ្នា។ ឧទាហរណ៍ៈ ត្រូវធ្វើការវាយតម្លៃ EIA រឺចំពោះសកម្មភាពដូចតទៅនេះ (ក) ទំនប់វារីអគ្គិសនី (ខ) ប្រព័ន្ធស្រោចស្រព (គ) សំណង់កំពង់ផែ និង(ឃ) ការជីកស្តារ ។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ស្តី





ពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ពុំបានកំណត់អំពីនីតិវិធី EIA រឺធ្វើ-សេចក្តីបកស្រាយថា តើត្រូវមានអ្វីខ្លះនោះទេ។

អនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩) បានចែងពីការទទួលខុសត្រូវរបស់ក្រសួងបរិស្ថានលើការបង្កើតគោលការណ៍ណែនាំសំរាប់ EIA។ ក្រសួងបរិស្ថានក៏បានផ្ទេរការទទួលខុសត្រូវនេះជាបន្តទៅនាយកដ្ឋានតាមដាន និងវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ទោះបីនាយកដ្ឋាននេះ នៅពុំទាន់បានអនុម័តគោលការណ៍ណែនាំស្តីពី EIA ក៏ដោយ មានឯកសារចំនួនពីរកំពុងត្រូវបានរៀបចំដើម្បីកែលំអដំណើរការ EIA ដែលមានឈ្មោះថា "ការអនុវត្តដំណើរការត្រួតពិនិត្យបរិស្ថាន" និង "គោលការណ៍ណែនាំសំរាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន"។

ការគ្រប់គ្រង និងពង្រឹងការអនុវត្តន៏តាមលក្ខខណ្ឌនៃ EIA ក្នុងប្រទេសកម្ពុជាប្រឈមនឹងឧបសគ្គមួយចំនួន។ ទីមួយ លក្ខខណ្ឌនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅពុំទាន់បានជ្រួតជ្រាបទូលំទូលាយ ហេតុនេះក្រសួងនានា និងម្ចាស់គម្រោងនៅពុំទាន់អនុវត្តតាមលក្ខខណ្ឌនោះនៅឡើយទេ។ សមត្ថកិច្ចរបស់ក្រសួងបរិស្ថានក្នុងការចាប់បង្ខំឱ្យអនុវត្តតាមលក្ខខណ្ឌទាំងនោះ ក៏នៅ មានកម្រិតកំណត់ ដោយសារកាលៈទេសៈទាំងនេះ។ បញ្ហាមួយផ្សេងទៀត គឺសមត្ថភាពដែលនៅមានកម្រិតទាបនៅឡើយក្នុងប្រទេសកម្ពុជាក្នុងការអនុវត្តន៏ដំណើរការ EIA។ នៅក្នុងប្រទេសមានអ្នកឯកទេសមួយចំនួនតូចតែប៉ុណ្ណោះដែលមានបទពិសោធន៏អំពីការរៀបចំរបាយការណ៍ EIA អាស្រ័យហេតុនេះ ក្រុមហ៊ុនអន្តរជាតិដែលផ្តល់សេវាលើផ្នែកនេះច្រើនតែត្រូវបានជួលឱ្យអនុវត្តការងារនេះ ហេតុនេះត្រូវចំណាយខ្ពស់ និងពុំនាំឱ្យមានការកសាងសមត្ថភាពនៅក្នុងស្រុកដើម្បីអនុវត្តការងារនេះផងទេ។

តម្រូវការធ្វើការវាយតម្លៃបរិស្ថាននៅក្នុងប្រទេសកម្ពុជា ភាគច្រើននៅត្រូវបាន

ចាត់ទុកជាអាទិភាពទីពីរធៀបនឹងតម្រូវការអភិវឌ្ឍ ។ សារៈសំខាន់នៃ EIA នៅពុំទាន់បានការទទួលការយកចិត្តទុកដាក់នៅឡើយទេ ដូចជាក្នុងចំណោមក្រសួងជាច្រើនរបស់រដ្ឋាភិបាលដែលទទួលខុសត្រូវលើការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ វារីឧស្សាហកម្ម និងកសិកម្ម ។

---

IUCN
Mekong Region Water Resources Decision-making: National Policy and Legal Frameworks 2006

(ការអភិវឌ្ឍន៍ធនធានទឹកនៃប្រទេសកម្ពុជាៈ ការពិនិត្យមើលគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ដែលមានស្រាប់)

ដោយលោក សំ ចំរើន ប្រធាននាយកដ្ឋានផែនការ និងកិច្ចការច្បាប់
ក្រសួងបរិស្ថាន វុក្ខវិថីព្រះសីហនុ ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
អ៊ីម៉ែលៈ chamroeunsam@hotmail.com





# ចំណេះដឹងទូទៅៈ ☞ សំណួរ-ចម្លើយ

ដកស្រង់ពីសៀវភៅរបស់
វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស

**ស្តីពីៈ សិទ្ធិមនុស្ស រដ្ឋធម្មនុញ្ញ ពលរដ្ឋវិទ្យា ប្រជាធិបតេយ្យ តួនាទី និងភារកិច្ចថ្នាក់ដឹកនាំ និងដំណោះស្រាយជម្លោះ**

**ប្រទេសកម្ពុជាបានចុះហត្ថលេខាចូលជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅថ្ងៃ ទី ២០ មេសា ១៩៩២ ។ ក្នុងនោះមានសិទ្ធិពលរដ្ឋយ៉ាងតិច ៤៦ប្រភេទ តើមានអ្វីខ្លះ?**

**☑ សិទ្ធិទាំង ៤៦ ប្រភេទគឺ :**

១. សិទ្ធិដើម្បីរស់រានមានជីវិត គឺមិនស្លាប់ និងការពារជីវិតឱ្យគង់វង្ស

២. សិទ្ធិដើម្បីមានសេរីភាព បំបិទសេរីភាព គឺជាការរំលោភសិទ្ធិ

៣. សិទ្ធិរួចផុតពីការធ្វើទារុណកម្ម ទារុណកម្មគ្រប់ប្រភេទត្រូវហាមដាច់ខាត

៤. សិទ្ធិស្មើគ្នានៅចំពោះមុខច្បាប់ គឺច្បាប់ត្រូវការពារ និងផ្តន្ទាទោសមនុស្សស្មើៗគ្នា

៥. សិទ្ធិរួចផុតពីការរើសអើង គឺមិនត្រូវប្រកាន់បក្សពួក វណ្ណៈ ឋានៈ ។ល។

៦. សិទ្ធិឱ្យមានច្បាប់ការពារ គឺត្រូវមានច្បាប់គ្រប់គ្រាន់សំរាប់ការពារមនុស្សលើគ្រប់វិស័យ

៧. សិទ្ធិដើម្បីមានសញ្ជាតិមួយ គឺឱ្យតែមនុស្សត្រូវតែមានសញ្ជាតិ

៨. សិទ្ធិមានឈ្មោះមួយ

៩. សិទ្ធិប្រព្រឹត្តតាមដំណើរការច្បាប់ គឺត្រូវប្រតិបត្តិតាមលំនាំច្បាប់

១០. សិទ្ធិប្រើប្រាស់ប្រព័ន្ធតុលាការ គឺចេញចូលតុលាការបានតាមត្រូវការ

១១. សិទ្ធិមានការជំនុំជំរះក្តី ដោយអាជ្ញាធរមានសមត្ថកិច្ច មិនលំអៀង និងឯករាជ្យ គឺមាន

តែតុលាការទេ ដែលមានសមត្ថកិច្ចកាត់សេចក្តី ហើយអង្គចៅក្រមត្រូវតែអព្យាក្រិត ឥតលំអៀង និងឯករាជ្យ

១២. សិទ្ធិមានការជំនុំជំរះក្តីជាសាធារណៈ គឺតុលាការជំរះក្តីដោយមានសាធារណជនចូលស្តាប់ផង

១៣. សិទ្ធិទទួលព័ត៌មានស្តីពីការចោទប្រកាន់ គឺបើក្រសួងធ្វើការចោទប្រកាន់ជនណាម្នាក់ ត្រូវតែប្រាប់មូលហេតុនៃការចោទប្រកាន់នេះ

១៤. សិទ្ធិសន្មតជាមុនថាជាមនុស្សគ្មានកំហុស គឺបើតុលាការមិនទាន់រកភស្តុតាងថាជនណាបាន ប្រព្រឹត្តកំហុសទេ ត្រូវចាត់ទុកជននោះថាជាជនគ្មានកំហុស

១៥. សិទ្ធិមិនឱ្យគេបង្ខំឱ្យបង្ហាញភស្តុតាង ដែលជាប់ជំពាក់ក្នុងបទឧក្រិដ្ឋដោយខ្លួនឯង គឺមិន ត្រូវបង្ខំឱ្យជនដែល ជាប់សង្ស័យបង្ហាញភ័ស្តុតាងទម្លាក់កំហុសលើខ្លួនឯងឡើយ

១៦. សិទ្ធិអាចទារយកព័ត៌មានដែលជាប់ទាក់ទងនឹងខ្លួន

១៧. សិទ្ធិមានការឧបត្ថម្ភសេវាច្បាប់ដោយឥតគិតឈ្នួល គឺបើជនជាប់ចោទមិនមានប្រាក់ជួល អ្នកការពារក្តីទេ ក្រសួង ឬស្ថាប័នឯទៀតដែលទាក់ទិនត្រូវផ្តល់ឱ្យ

១៨. សិទ្ធិជ្រើសរើសសេវាច្បាប់ការពារខ្លួន គឺជនជាប់ចោទអាចទទួលយកស្នាក្តីដែលរដ្ឋផ្តល់ ឱ្យ ឬបើមានប្រាក់ គេអាចជួលស្នាក្តីដោយខ្លួនឯង

១៩. សិទ្ធិមានពេលវេលា និងមានលទ្ធភាពរៀបចំកិច្ចការពារខ្លួនតាមផ្លូវច្បាប់ គឺមុននឹងនាំជន ជាប់ចោទទៅជំរះក្តី ត្រូវទុកពេលឱ្យជននោះរកស្នាក្តីដើម្បីសិក្សាសំណុំរឿង និងរៀបចំ ការពារក្តីឱ្យគេ

២០. សិទ្ធិការពារ និងសិទ្ធិឆ្លើយដោះសាដោយផ្ទាល់ គឺដាច់ខាតត្រូវផ្តល់លទ្ធភាពឱ្យជនជាប់ ចោទឆ្លើយឆ្លងឱ្យបានគ្រប់គ្រាន់ដើម្បីការពារខ្លួន

២១.សិទ្ធិមានការទាក់ទងជាមួយស្នាក្តី គឺត្រូវអនុញ្ញាតឱ្យជនដែលនៅក្នុងមន្ទីរឃុំឃាំង ឬក្នុង គុក មានការទាក់ទងជាអ្នកការពារក្តីតាមត្រូវការ





២២. សិទ្ធិមានជំនួយពីអ្នកបកប្រែភាសាដោយឥតគិតឈ្នួល គឺបើកាត់ទោសលើជនបរទេស ក្រសួង ឬស្ថាប័នពាក់ព័ន្ធត្រូវផ្តល់អ្នកបកប្រែភាសា

២៣. សិទ្ធិមានលទ្ធភាពតក្តីស្មើគ្នា ចំពោះអំណាចច្បាប់

២៤. សិទ្ធិមានការពិនិត្យពិច័យលើសាក្សី គឺអ្នកការពារក្តីអាចសួរដេញដោលសាក្សីដើមចោទ

២៥. សិទ្ធិឱ្យតុលាការប្រតិបត្តិតាមនិតិវិធី គឺការកាត់ទោសមិនស្របតាមនីតិវិធីនឹងទុកជាឥត បានការ

២៦. សិទ្ធិទទួលការដោះស្រាយដោយប្រសិទ្ធភាព គឺនៅក្នុងដំណើរការកាត់ក្តីតុលាការត្រូវ ដោះស្រាយបញ្ហានានាដោយវិធីឆាប់រហ័ស និងវាងវៃ

២៧. សិទ្ធិមិនត្រូវមានទោសបញ្ញត្តិដែលមានប្រតិកម្មធាក់ថយ

២៨. សិទ្ធិសុំប្តឹងឧទ្ធរណ៍ គឺបើភាគីណាមិនសុខចិត្តចំពោះសេចក្តីសម្រេចនៃតុលាការថ្នាក់ក្រោម ទេ គេអាចប្តឹងតវ៉ាទៅតុលាការថ្នាក់លើទៀត

២៩. សិទ្ធិមានការគ្រប់គ្រងដោយមនុសសធម៌ គឺមិនត្រូវផ្តន្ទាទោស ឬប្រព្រឹត្តអំពើឃោរឃៅ អមនុស្សធម៌លើជនណាឡើយ

៣០. សិទ្ធិមានការគ្រប់គ្រងសមរម្យជាអ្នកទោស គឺត្រូវទុកដាក់អ្នកទោសឱ្យសមស្របតាម បទដ្ឋាននៃការគ្រប់គ្រងអ្នកទោស

៣១. សិទ្ធិការពារពីការរំលោភរបស់អាជ្ញាធរ គឺត្រូវមានច្បាប់សំរាបទប់ស្កាត់ និងផ្តន្ទាទោស មន្ត្រីរាជការដែលប្រព្រឹត្តរំលោភលើរាស្ត្រស្លូតត្រង់

៣២. សិទ្ធិទទួលយក ស្វែងរក និងចែកចាយព័ត៌មាន គឺមិនត្រូវហាមឃាត់មិនឱ្យយកព័ត៌មាន និងចែកចាយព័ត៌មានឡើយ

៣២. សិទ្ធិមានមនសិការ និងបញ្ចេញមតិដោយសេរី រួមទាំងជំនឿសាសនា និងជំនឿនយោបាយ

៣៤. សិទ្ធិមានសន្តិសុខក្នុងលំនៅដ្ឋានឯកជនរបស់ខ្លួន គឺមិនត្រូវយាយីលំនៅស្ថានគេឡើយ

៣៥. សិទ្ធិមាននិរភ័យក្នុងទំនាក់ទំនងផ្ទាល់ខ្លួន គឺមិនត្រូវជ្រៀតជ្រែកក្នុងកិច្ចការរបស់អ្នកដទៃ ជាអាទិ៍ ការទាក់ទងផ្ទាល់ខ្លួន

៣៦. សិទ្ធិមានកិច្ចការពារកិត្តិយស និងកិត្តិស័ព្ទ គឺត្រូវមានច្បាប់ការពារកុំឱ្យមានការប៉ះពាល់ដល់កិត្តិស័ព្ទ និងកិត្តិយស

៣៧. សិទ្ធិធ្វើដំណើរដោយសេរី ប៉ុន្តែបើចូលទៅប្រទេសដទៃ ត្រូវមានការអនុញ្ញាតពីប្រទេសនោះ

៣៨. សិទ្ធិតាំងលំនៅស្ថានដោយសេរី ប៉ុន្តែត្រូវឱ្យសមស្របតាមច្បាប់សំណង់

៣៩. សិទ្ធិមានសំណងជម្ងឺចិត្តក្នុងករណីមានការខុសឆ្គោយខាងយុត្តិធម៌ បើកាត់ទោសជនណាម្នាក់ខុស ត្រូវតែសងជំងឺចិត្តជននោះ

៤០. សិទ្ធិរួចផុតពីការធ្វើពិសោធន៍ខាងពេទ្យ ឬខាងវិទ្យាសាស្ត្រដោយគ្មានការព្រមព្រៀង បើគ្មានការព្រមព្រៀងដោយសេរីពីសាមីខ្លួនទេ គឺមិនអាចធ្វើការពិសោធន៍លើជននោះឡើយ

៤១. សិទ្ធិរៀបអាពាហ៍ពិពាហ៍ រួមមានសិទ្ធិបដិសេធមិនព្រមរៀបអាពាហ៍ពិពាហ៍ ដោយគ្មានការសុខចិត្តដោយសេរី និងពេញលេញ

៤២. សិទ្ធិមិនឱ្យគេដកហូតទ្រព្យសម្បត្តិតាមអំពើចិត្ត គឺដោយគ្មានបញ្ជាពីតុលាការ

៤៣. សិទ្ធិរួចផុតពីការជាប់ពន្ធនាគារដោយសារការជាប់ជំពាក់បំណុលគេ គឺមិនត្រូវយកមនុស្សទៅដាក់គុកដោយសាររឿងជំពាក់បំណុលឡើយ

៤៤. សិទ្ធិមិនត្រូវគេនិរទេសដោយគ្មានបញ្ជាពីតុលាការ គឺមានតែស្ថាប័នតុលាការទេ ដែលមានអំណាចសម្រេចនិរទេសមនុស្ស

៤៥. សិទ្ធិចាកចេញពីប្រទេស និងសិទ្ធិត្រឡប់ចូលមកក្នុងប្រទេសវិញ

៤៦. សិទ្ធិមិនចូលបំរើកងទ័ពដោយសំអាងទៅលើលទ្ធិ ឬជំនឿសាសនាអ្វីមួយ

(តទៅលេខក្រោយ)



ព្រឹត្តិបត្រ ធម្មជាតិ និង ជីវិត មករា_កុម្ភៈ ២០០៨



# សង្ខេបព័ត៌មានជុំវិញបរិស្ថាន

ដកស្រង់ និងសង្ខេប
ដោយលោក ប៉ែន មិថុនា

## កម្ពុជាសម្បូរទីតាំងដ៏មានសក្តានុពលសម្រាប់អភិវឌ្ឍន៍វារីអគ្គិសនី តែគួរប្រយ័ត្នចំពោះសក្តានុពលនេះ

អ្នកជំនាញការខាងបរិស្ថានមួយរូបបាននិយាយក្នុងលក្ខខណ្ឌមិនបញ្ចេញឈ្មោះថា ដើម្បីធានាឱ្យមានការអភិវឌ្ឍន៍វារីអគ្គិសនីនៅក្នុងប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព កម្ពុជាគួរតែប្រយ័ត្នប្រយែងចំពោះរាល់ការសម្រេចចិត្តណាមួយលើគម្រោងវិនិយោគវារីអគ្គិសនីនៅក្នុងប្រទេស។ យោងតាមសេចក្តីព្រាងរបស់អង្គការចាយកា (JICA) ស្តីអំពីការសិក្សាលើផែនការមេលើគម្រោងអភិវឌ្ឍន៍វារីអគ្គិសនីនៅក្នុងប្រទេសកម្ពុជា ហើយបានចេញកាលពីពេលកន្លងទៅនេះបានឱ្យដឹងថា កម្ពុជាមានទីតាំងភូមិសាស្ត្រប្រមាណជា២៩កន្លែងដែលអាចឱ្យគេអភិវឌ្ឍន៍ធ្វើជាទំនប់វារីអគ្គិសនីបាន។ កន្លែងទាំងអស់នោះយ៉ាងហោចណាស់ក៏អាចវិនិយោគកសាងទំនប់វារីអគ្គិសនីផ្តល់ថាមពលលើសពី១០មេហ្គាវ៉ាត់ដែរនៅក្នុងមួយកន្លែងៗ។ អ្នកជំនាញការរូបនោះបានបន្តថា នេះគឺជាអំណោយផលពីធម្មជាតិមួយរបស់ប្រទេសកម្ពុជា តែយើងគួរតែទាញយកអំណោយផលនេះដោយប្រយ័ត្នប្រយែង ដើម្បីកុំឱ្យអំណោយផលទាំងនេះប្រែក្លាយទៅជាទណ្ឌកម្មធម្មជាតិវិញ។ លោកបានបញ្ជាក់ថា "ការអភិវឌ្ឍន៍វារីអគ្គិសនីងាយនឹងរងផលប៉ះពាល់ណាស់បើមិនប្រយ័ត្នប្រយែង និងសិក្សាឱ្យបានច្បាស់លាស់នោះទេ។ រាល់ការអភិវឌ្ឍន៍វារីអគ្គិសនីតែងតែចៀសមិនរួចឡើយពីផលប៉ះពាល់គ្រាន់តែតិច និងច្រើន"។ ទាក់ទងនឹងផលប៉ះពាល់នេះ របាយការណ៍មួយដែលគេសិក្សាអំពីផលប៉ះពាល់នៃការ

អភិវឌ្ឍវារីអគ្គិសនីនឹងត្រូវចេញផ្សាយនៅពេលឆាប់ៗខាងមុខ។

**(រស្មីកម្ពុជា ថ្ងៃទី២៧-២៩ ខែមករា ឆ្នាំ២០០៨)**

## ឈើប្រណីតកំពុងសម្រុកដឹកចូលទីរួមខេត្តស្ទឹងត្រែង

ឈើប្រណីតកំពុងសម្រុកដឹកចូលទីរួមខេត្តស្ទឹងត្រែងតាមទូកទាំងថ្ងៃទាំងយប់ បន្ទាប់ពីសកម្មភាពនាំឈើប្រណីតនេះស្ងាត់បានបន្តិចរួមមក។ ប្រភពព័ត៌មានពីខេត្តស្ទឹងត្រែងបានឱ្យដឹងថា នៅព្រឹកថ្ងៃ ទី២៩ ខែមករា ឆ្នាំ២០០៨ មានឈើប្រណីតចំនួន៤ទូក ត្រូវបានឈ្មួញរកស៊ីឈើដឹកចេញពីស្រុកសៀមប៉ាងចូលមកទីរួមខេត្តស្ទឹងត្រែង។ ឈើប្រណីតចំនួន៤ទូកនោះគឺជាប្រភេទឈើគ្រញូងចំនួន៣ទូក និងឈើបេងចំនួន១ទូក។ អ្នកដែលនាំឈើប្រណីតទាំងនោះគឺជាមន្ត្រីយោធាសីករងខេត្តស្ទឹងត្រែង ដោយក្នុងឈើប្រណីតមួយទូករត់ការសមត្ថកិច្ចទាំងអស់ពីស្រុកសៀមប៉ាងរហូតមកដល់ទីរួមខេត្តស្ទឹងត្រែងត្រូវចំណាយអស់១000ដុល្លារ។ គេបានឱ្យដឹងទៀតថា ឈើប្រណីតទាំង៤ទូកនោះពេលលើកចេញពីទូកដាក់នៅទីរួមខេត្តស្ទឹងត្រែង ហើយក៏មានឈ្មួញទៅពីខេត្តក្រចេះមកទិញ ហើយដឹកតាមរថយន្តកាមរី និងរថយន្តទូរីសយកទៅលក់បន្តនៅព្រំដែនវៀតណាម។ ចំពោះឈើប្រណីតដែលមានមន្ត្រីយោធា និងកូនប្រធានមន្ទីរអធិការកិច្ចខេត្តស្ទឹងត្រែងនាំចេញពីស្រុកសៀមប៉ាងនោះ គឺសុទ្ធតែឈើដែលមានមុខកាត់ធំៗ។

**(រស្មីកម្ពុជា ថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨)**

## បទល្មើសចាប់ឈើប្រណីតកំពុងកើតមានយ៉ាងធ្ងន់ធ្ងរនៅស្រុកថាឡាបរិវ៉ាត់

សកម្មភាពលួចកាប់ឈើប្រណីតដោយខុសច្បាប់កំពុងតែកើតមានយ៉ាងធ្ងន់ធ្ងរនៅក្នុងភូមិសាស្ត្រស្រុកថាឡាបរិវ៉ាត់ ខេត្តស្ទឹងត្រែងដោយមានមន្ត្រីរដ្ឋបាលព្រៃឈើនៅទីនោះជាអ្នកបើកដៃឱ្យ។ ប្រភពព័ត៌មានពីអាជ្ញាធរស្រុកថាឡាបរិវ៉ាត់បានបញ្ជាក់ថា សព្វថ្ងៃនៅក្នុងស្រុកនេះមានសិប្បកម្មសម្រាប់កែច្នៃឈើប្រណីតទាំងអស់ចំនួន១០កន្លែង ដែលគ្មានច្បាប់អនុញ្ញាតពីខណ្ឌរដ្ឋបាលព្រៃឈើស្ទឹងត្រែងនោះទេ។ សិប្បកម្មទាំងអស់នោះគឺជាប្រភពប្រមូលទិញឈើប្រណីតខុសច្បាប់ពីព្រៃ ហើយក៏ជាប្រភពសម្រាប់ផ្គត់ឈើបន្តឱ្យសិប្បកម្ម ដែលអត់ច្បាប់ជាច្រើនទៀតនៅក្នុងទីរួមខេត្តស្ទឹងត្រែងផងដែរ។ ប្រភពពីអ្នកភូមិបាននិយាយថា ម្ចាស់សិប្បកម្មភាគច្រើននៅទីរួមខេត្តស្ទឹងត្រែង និងនៅក្នុងស្រុកថាឡាបរិវ៉ាត់គឺជាអ្នកផ្គត់ផ្គង់លុយកាក់រណារយន្ត និងប្រេងជាដើមដល់ប្រជាពលរដ្ឋឱ្យចូលទៅកាប់យកឈើប្រណីតពីក្នុងព្រៃ ហើយដឹកយកមកលក់ឱ្យពួកគេដោយទូទាត់គ្នាជាមួយតម្លៃឈើ។ ដោយសារតែមានការផ្គត់ផ្គង់ទាំងនោះ ព្រមទាំងមានការឃុបឃិតគ្នាពីមន្ត្រីរដ្ឋបាលព្រៃឈើ បានជំរុញឱ្យសកម្មភាពកាប់ឈើប្រណីតកាន់តែមានភាពអនាធិបតេយ្យ។ ឈើទាំងនោះត្រូវបានគេដឹកតាមរថយន្ត តូច-ធំ គោយន្តកែច្នៃ និងតាមរទេះគោក្របីមកដាក់តាមសិប្បកម្ម រួចដឹកបន្តយកទៅលក់នៅតាមកន្លែងផ្សេងៗ។ មានសិប្បកម្មកែច្នៃឈើខ្លះដូចជានៅជាប់នឹងច្រមុះស្នាក់ការផ្នែករដ្ឋបាលព្រៃឈើថាឡាបរិវ៉ាត់នោះ គឺជារបស់មន្ត្រីយោធាខេត្តស្ទឹងត្រែងឈ្មោះ ជិន ហេង ដែលអ្នករស់នៅជិតនោះចាត់ទុកថាអ្នកឈ្មួញរកស៊ីឈើដ៏ធំដោយសារត្រូវរ៉ូវគ្នាជាមួយមន្ត្រីរដ្ឋបាលព្រៃឈើនៅទីនោះតែប៉ុណ្ណោះ។ មន្ត្រីក្រុមប្រឹក្សាឃុំថាឡាបរិវ៉ាត់មួយរូបបានបញ្ជាក់ថា "យើងចង់រួមចំណែកបង្ក្រាបសកម្មភាពរកស៊ីឈើប្រណីតនេះណាស់ តែមិនអាចធ្វើទៅបានព្រោះជំនាញព្រៃឈើ គឺជាបើកដៃឱ្យឈ្មួញរកស៊ីដោយចំហរទៅហើយ"។

លោកអភិបាលស្រុកថាឡាបរិវ៉ាត់បានបញ្ជាក់ដែរថា កន្លងមក កម្លាំងសមត្ថកិច្ចនៅខេត្តមួយចំនួន តែងតែចុះមកស្រុកថាជួយបង្ក្រាបបទល្មើសព្រៃឈើ។ ប៉ុន្តែបើពិនិត្យទៅ គឺគេចុះមកយកតែលុយប៉ុណ្ណោះ។ មន្ត្រីសមត្ថកិច្ចមួយចំនួនដែលចុះទៅពីខេត្តបានចោទប្រកាន់វិញថា គឺអាជ្ញាធរស្រុកថាឡាបរិវ៉ាត់វិញទេដែលជាអ្នកបើកដៃឱ្យឈ្មួញរកស៊ីកាប់ឈើប្រណីតដោយខុសច្បាប់នោះ។ លោក ទៀង ដារិត នាយផ្នែករដ្ឋបាលព្រៃឈើថាឡាបរិវ៉ាត់បានបញ្ជាក់តាមទូរស័ព្ទថា សិប្បកម្មទាំងអស់នៅថាឡាបរិវ៉ាត់នោះគ្រាន់តែជារោងជាងតូចតាចប៉ុណ្ណោះ។ លោកបញ្ជាក់ទៀតថា "នៅស្រុកព្រៃបើមិនឱ្យមានរោងជាងខ្លះធ្វើម៉េចនឹងបានអ្វីរកស៊ី"។

**(រស្មីកម្ពុជា ថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៨)**

កំណាព្យ

# ទំនួញព្រៃឈើ

និពន្ធដោយៈ ឌូក រិទ្ធី

\- ដីខ្មែរខេមរាដ៏ឧត្តម សូរសព្ទរណ្តំពេញទិសា
ដោយមានធនធានព្រៃបុព្វតា ដំណែលជូនតាច្រើនសន្ធឹក ។

\- ឥឡូវរូបខ្ញុំប្រែរូបកាយ មនុស្សសើចក្អាកក្អាយឥតមាននឹក
បំភ្លេចអស់គុណមានរដឹក បើពុំរំលឹកមិនព្រមភ្ញាក់ ។

\- រដូវវស្សាទឹកជំនន់ ហូរច្រោះស្ទួនៗយ៉ាងសស្រាក់
រូបខ្ញុំនេះហើយការពារអ្នក ជារបងទាក់រនាំងទប់ ។

\- មានខ្ញុំជាគ្នាអ្នកសុខសាន្ត ជំនន់សាមានត្រូវបានឈប់
មិនថាពេលថ្ងៃ រឺ ពេលយប់ អ្នកដេកបានស្កប់អស់ទុក្ខព្រួយ ។

\- គិម្ហរដូវក្តៅហួតហែង ចិត្តអ្នកចំបែងស្វែងជំនួយ
មានដីងរឺ ទេខ្ញុំនេះហើយ ថែរក្សាជួយអ្នកគ្រប់ប្រាណ ។

\- ពន្លឺសូរ្យសែងបែងកំដៅ លើភពអ្នកនៅសព្វសណ្ឋាន
ដីបែកក្រហែងពុំនឹកស្មាន ខ្ញុំជួយឱ្យបានប្រសើរលៃ ។

\- រូបខ្ញុំជាម្លប់គាប់ចន្ទា សំរួលកាយាស្តារយកជ័យ
ជំនួយដល់អ្នកទាំងយប់ថ្ងៃ ម្តេចអ្នកពុំលៃអោយបានច្បាស់ ។

\- ជូនជាអាសន្នស្លន់មកដល់ គ្រូម៉ពុំខ្វល់អង្វរព្រះ
បើមានពួកខ្ញុំនៅជិតផ្ទះ នោះគ្រូម៉ចាស់ផ្សំប្រពៃ ។

\- ពេលនេះរូបខ្ញុំជាថ្នាំទិព្វ អ្នកមកនេបនិត្យឥតសង្ស័យ
លុះផុតទុក្ខភ័យអ្នកប្រល័យ ពុំមានសំចៃដៃសោះឡើយ ។

\- ន្ទើយ! សូមរៀបរាប់ប៉ុណ្ណឹងចុះ ព្រោះឥតរឿងនោះរាប់ពុំស្បើយ
ទោះពេលអ្នកចាកលោកទៅហើយ ខ្ញុំជាខ្មើយកើយ ក្តាមឈូសទៀត ។

\- ខ្ញុំសូមអង្វរចិត្តលោកអ្នក មេត្តាទំលាក់គ្រឿងបៀនបៀត
បំផ្លាញយើងខ្ញុំឱ្យឃ្លៀងឃ្លាត ចាកលោកីយទៀតណាលោកអើយ ។

\- និងសូមអរគុណជនអភិរក្ស ខំដោយស្មោះស្មាក់ឥតកន្តើយ






## សមាគមថែរក្សាបរិស្ថាន និងវប្បធម៌

អាស័យដ្ឋាន : ផ្ទះលេខ ៥៩ ផ្លូវលេខ ១៥៦ ស,ង ផ្សារដេប៉ូរ ១ ខ័ណ្ឌទួលគោក ភ្នំពេញ
ទូរស័ព្ទ និងទូរសារ : ០២៣ ៨៨១ ៦១៣ និង ០២៣ ៣៦៩ ១៧៩
ទូរស័ព្ទចល័ត : ០១២ ៧៧២ ២៨២ និង ០១២ ៧៩៣ ៤៨៩
ប្រអប់សំបុត្រ : P.O Box 1486, CCC Box. 357
សារអេឡិចត្រូនិក : mkr@cepa-cambodia.org
គេហទំព័រ : www.cepa-cambodia.org



### គណៈកម្មការត្រួតពិនិត្យ

- ☑ លោក ប៊ូ សារឿន
- ☑ លោក ទេព បុណ្ណារិទ្ធិ
- ☑ លោកស្រី លុយ រស្មី
- ☑ លោក តឹក វណ្ណារ៉ា

### ក្រុមការងារនិពន្ធ និងរៀបចំ

- ✍ លោក ប៉ែន មករា
- ✍ លោក ប៉ែន មិថុនា




ដំណើរទស្សនកិច្ចសិក្សារបស់ភ្ញៀវជាតិ និងអន្តរជាតិ នៅសហគមន៍ទេសចរណ៍ធម្មជាតិ បូរីអូរស្វាយ

ឧបត្ថម្ភមូលនិធិដោយ: OGB, OA, Forum Syd, SSNC and Mcknight Foundation

បោះពុម្ពដោយរោងពុម្ពរស្មីជាតិ